ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# បញ្ហាប្រឈម តម្រូវការ និងសំណើ របស់ប្រជាពលរដ្ឋងាយរងគ្រោះ សុំឱ្យមានកិច្ចអន្តរាគមន៍គោលនយោបាយ ពីថ្នាក់ដឹកនាំ និងអ្នកតាក់តែង គោលនយោបាយ។



# ទិវាអន្តរជាតិនារី ខួបលើកទី ១១២
# គាំពារស្ត្រី និងក្មេងស្រី ដើម្បីយុត្តិធម៌ទាំងអស់គ្នា

ទិវាអន្តរជាតិនារីគឺជាទិវាមួយដែលនារីនៅជុំវិញពិភពលោកបានប្រារព្ធពិធីនេះឡើងដើម្បីរំលឹកដល់ការតស៊ូរបស់ខ្លួនដោយចម្រុះជាតិសាសន៍បើទោះមានភាសា ពណ៌ សម្បុរ វប្បធម៌ សេដ្ឋកិច្ច និងនយោបាយខុសគ្នាយ៉ាងណាក្តី។ បើយើងប្រៀបធៀបប្រវត្តិអន្តរជាតិនារី ៨ មីនា ទៅនឹងកំណើតនៃអង្គការសហប្រជាជាតិ ឃើញថាប្រវត្តិទិវាអន្តរជាតិនារី ៨ មីនា មានកំណើតមុនអង្គការសហប្រជាជាតិ និងទិវាសិទ្ធិមនុស្សអន្តរជាតិទៅទៀត។

ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រី (CEDAW) ក្នុងឆ្នាំ១៩៩២ ហើយនៅឆ្នាំ២០១០ រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់សច្ចាប័នលើពិធីសារជម្រើស (Option Protocol to CEDAW)។ ស្របពេលដែលមាត្រា៣១នៃរដ្ឋធម្មនុញដែលជាច្បាប់កំពូលក៏បានចែងយ៉ាងច្បាស់ពីការលើកកម្ពស់សិទ្ធិនារី និងកុមារ។ រយៈពេល៣ទសវត្សរ៍កន្លងទៅនេះរដ្ឋាភិបាលកម្ពុជា និងអង្គការសង្គមស៊ីវិលពាក់ព័ន្ធទាំងអស់បានខិតខំប្រឹងប្រែងសហការណ៍ដើម្បីធ្វើការរួមគ្នាក្នុងគោលដៅលើកម្ពស់សិទ្ធស្ត្រី និងប្រឆាំងការរើងអើងគ្រប់រូបភាពជាពិសេសផ្តោតសំខាន់ទៅលើសមភាពយេនឌ័រ។

បើទោះជាកិច្ចខិតខំប្រឹងប្រែងនេះបានកំពុងបន្តអស់រយៈជិត៣០ឆ្នាំក៏ដោយ ក៏ប៉ុន្តែយើងសង្កេតឃើញថាការរំលោភបំពាន ការរើសអើងមកលើស្ត្រីនៅតែបន្តកើតមានឡើងស្ទើតែគ្រប់វិស័យ ដូចជាការធ្វើទុក្ខបុកម្នេញមកលើសកម្មជនស្ត្រីដែលជាតំណាងសហជីព ការរើសអើងស្ត្រីដែលជាសកម្មជនដីធ្លី ការរិតត្បិតសិទ្ធិសេរីរបស់ស្ត្រីដែលជាសកម្មជននយោបាយ ការប្រើប្រាស់អំពើហិង្សាមកលើស្ត្រីក្នុង សកម្មភាពតវ៉ានានា និងការបៀតបៀនស្ត្រីតាមគ្រប់មធ្យោបាយ ។

ជាក់ស្តែងការលើកកម្ពស់សិទ្ធិស្ត្រី និងក្មេងស្រីនៅកម្ពុជានៅមានកម្រិតទាបនៅឡើយ ហើយរាជរដ្ឋាភិបាលក៏គួរតែកែលម្អនូវភាពខ្វះចន្លោះនៃច្បាប់ និងគោលនយោបាយពាក់ព័ន្ធនានាជាពិសេសការអនុវត្តច្បាប់ដើម្បីធានាការពារសិទ្ធិ និងលើកកម្ពស់ការចូលរួមរបស់ស្ត្រីនៅក្នុងវិស័យសង្គម សេដ្ឋកិច្ច និងអភិបាលកិច្ច ព្រមទាំងផ្តល់ឱកាសបន្ថែមទៀតដល់ស្ត្រីជាពិសេសយុវវ័យនៅក្នុងតួនាទីធ្វើការសម្រេចចិត្តទាំងនៅក្នុងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិក៏ដូចជាបន្តកសាង និងលើកកម្ពស់ស្ត្រី និងកុមារដើម្បីមានសមត្ថភាពគ្រប់គ្រាន់ក្នុងភាពជាអ្នកដឹកនាំដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព។

ស្ថានភាពកូវីត១៩បានធ្វើឱ្យជីវភាពរបស់អ្នកងាយរងគ្រោះត្រូវបានធ្លាក់ក្នុងស្ថានភាពរងគ្រោះជាងមុន បញ្ហាថ្មីកើតឡើងជាបន្ទុកធ្ងន់ដល់ពួកគេ។ តាមរយៈការបាត់បង់ចំណូល កើនឡើងបំណុល ការបាត់បង់ការងារ ការប្រែក្លាយពីកម្មករដែលស្ថិតនៅក្នុងប្រព័ន្ធដែលទទួលបានការចុះបញ្ជីពីបេឡាជាតិសន្តិសុខសង្គមទៅជាកម្មករសេដ្ឋកិច្ចក្រៅប្រព័ន្ធ លែងទទួលការការពារ និងគាំពារសង្គមពីកម្មវិធីបេឡាជាតិរបបសន្តិសុខសង្គម។ ដោយក្នុងស្ថានភាពនេះ និយោជកបានបិទសហគ្រាសដោយមិនមានទូទាត់សំណង។ និយោជក

យកហេតុផលដោយសារស្ថានភាពកូវីដ១៩បានរំសាយកម្មករនិងថ្នាក់ដឹកនាំសហជីព។ បើទោះបីរាជរដ្ឋាភិបាលបានធ្វើកិច្ចអន្តរាគមន៍តាមរយៈគោលនយោបាយក្តីក៏នៅមានចំនួនតិចតួចដែលត្រូវគ្របដណ្តប់ និងទទួលបានជំនួយឧបត្ថម្ភពីកម្មវិធីរបស់រាជរដ្ឋាភិបាលតាមរយៈប្រព័ន្ធជំនួយសង្គមនេះ។

ដូច្នេះដើម្បីចូលរួមអបអរយុទ្ធនាការអន្តរជាតិនារីឆ្នាំ២០២៣នេះ យើងខ្ញុំទាំងអស់គ្នាជាតំណាងសហជីពសម្ព័ន្ធសហជីព អង្គការសង្គមស៊ីវិល និងសមាគម ដែលកំពុងធ្វើការលើ ការងារចម្រុះវិស័យផ្នែកសិទ្ធិមនុស្ស សិទ្ធិការងារ និងសង្គម មានដូចជា ឧស្សាហកម្មកាត់ដេរ ចំណីអាហារ សេវាកម្ម សេដ្ឋកិច្ចក្រៅប្រព័ន្ធ មន្ត្រីរាជការ កម្មករសណ្ឋាគារ កាស៊ីណូ អ្នកធ្វើការតាមផ្ទះ កសិករ សហគមន៍ដីធ្លី និងបណ្តាញយុវជនបានរួមសហការគ្នារៀបចំទិវាអន្តរជាតិនារី ឆ្នាំ២០២៣ ក្រោមប្រធានបទ៖ គាំពារស្ត្រី និងក្មេងស្រីដើម្បីយុត្តិធម៌ទាំងអស់គ្នា ដោយលើកឡើងនូវសំណូមពរមួយចំនួនដល់រាជរដ្ឋាភិបាលកម្ពុជាជាពិសេសក្រសួងកិច្ចការនារី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងមហាផ្ទៃ និងក្រសួងការបរទេស គណៈកម្មការ ទប់ស្កាត់ការជួញដូរមនុស្ស ទីស្តីការគណៈរដ្ឋមន្ត្រី និងវិស័យឯកជនបន្តខិតខំប្រឹងប្រែងបន្ថែមទៀតក្នុងការឆ្លើយតបចំពោះតម្រូវការចាំបាច់ និងបន្ទាន់របស់ស្ត្រីដើម្បីលុបបំបាត់អំពើហិង្សាលើស្ត្រី និងក្មេងស្រីគ្រប់ទម្រង់ និងសម្រេចបាននូវគោលនយោបាយ និងផែនការយុទ្ធសាស្ត្រជាតិ ក្នុងការកាត់ បន្ថយវិសមភាពយេនឌ័រនិងភាពក្រីក្រនៅកម្ពុជា។

តម្រូវការដែលយើងធ្លាប់បានលើកឡើង និងស្នើសុំជាដំណោះស្រាយកន្លងមកជូនទៅកាន់ថ្នាក់ដឹកនាំ និងអ្នកតាក់តែងគោលនយោបាយគឺនៅមិនទាន់ទទួលបានការឆ្លើយតបពេញលេញក្នុងរូបភាពណាមួយឡើយ។ អាស្រ័យហេតុនេះ យើងខ្ញុំសូមលើកឡើងនូវបញ្ហាប្រឈម តម្រូវការ និងដំណោះស្រាយជាក់លាក់ដូចខាងក្រោម ជូនដល់ថ្នាក់ដឹកនាំក្រសួង-មន្ទីរពាក់ព័ន្ធ និងអ្នកតាក់តែងច្បាប់ដើម្បីពិនិត្យមើល និងផ្តល់កិច្ចអន្តរាគមន៍គោលនយោបាយ៖

| | |
|---|---|
| តម្រូវការទី ១ | បង្កើតមត្តេយ្យសហគមន៍ និងទារកដ្ឋាននៅតាមកន្លែងការងារ |
| តម្រូវការទី ២ | ជម្រកសុវត្ថិភាពសម្រាប់ស្ត្រីដែលជួបបញ្ហាអំពើហិង្សាក្នុងគ្រួសារ និងសម្រាប់កម្មករស្ត្រីដែលធ្វើការងារតាមផ្ទះ និងកម្មករចំណាកស្រុក |
| តម្រូវការទី ៣ | ចាត់វិធានការឱ្យមានប្រសិទ្ធភាពចំពោះអំពើហិង្សា និងការបៀតបៀនគ្រប់ទម្រង់មកលើស្ត្រីដោយគ្មានការលើកលែង |
| តម្រូវការទី ៤ | ចាត់វិធានរដ្ឋបាលជាក់លាក់ និងបញ្ឈប់ការប្រើប្រាស់អំពើហិង្សាលើស្ត្រីអ្នកការពារសិទ្ធិមនុស្ស សិទ្ធិដីធ្លី បរិស្ថាន និងសិទ្ធិការងារ |
| តម្រូវការទី ៥ | កំណែទម្រង់មធ្យោបាយដឹកជញ្ជូនកម្មករក្នុងវិស័យវាយនភ័ណ្ឌកាត់ដេរ និងដេរស្បែកជើង |
| តម្រូវការទី ៦ | កែលម្អលក្ខខណ្ឌការងារ និងពង្រឹងយន្តការការពារអ្នកធ្វើការងារតាមផ្ទះ |
| តម្រូវការទី ៧ | ពង្រឹងយន្តការការពារសិទ្ធិពលករចំណាកស្រុកពីការកេងប្រវ័ញ្ចពលកម្ម ការជួញដូរមនុស្ស និងទាសភាពសម័យទំនើប |

| | |
|---|---|
| តម្រូវការទី ៨ | ពង្រឹង និងពង្រីកវិសាលភាពនៃប័ណ្ណសមាជិក ប.ស.ស តាមរយៈការចុះធ្វើអធិការកិច្ច និងជំរុញឱ្យមានការចុះបញ្ជី និងបង់ភាគទាន ប.ស.ស. ក្នុងចំណោមនិយោជក ជាពិសេសគឺកម្មករនៅក្នុងវិស័យសំណង់ និងរោងចក្រកាត់ដេរ វាយនភ័ណ្ឌដែលធ្វើការស៊ីឈ្នួលដេរបន្ត (Sub-Contract) |
| តម្រូវការទី ៩ | រាជរដ្ឋាភិបាលត្រូវធានាថាកម្មករក្នុងវិស័យសំណង់ និងឡឥដ្ឋមានសម្ភារៈសុខភាព សុវត្ថិភាព ត្រឹមត្រូវតាមច្បាប់ និងសហគ្រាស គ្រឹះស្ថានបានចុះបញ្ជីជាសមាជិក ប.ស.ស |
| តម្រូវការទី ១០ | ពង្រីកវិសាលភាពនៃប្រព័ន្ធគាំពារសង្គមឱ្យបានដល់សមាជិកគ្រួសារ |
| តម្រូវការទី ១១ | ដាក់បញ្ចូល និងទទួលស្គាល់កសិករខ្នាតតូចនៅជនបទ ពិសេសកសិករជាស្ត្រីក្នុងគោលនយោបាយកិច្ចគាំពារសង្គម គាំទ្របណ្តុះបណ្តាលជំនាញ និងឧបត្ថម្ភទុនលើកសិករខ្នាតតូច |
| តម្រូវការទី ១២ | រាជរដ្ឋាភិបាលត្រូវរៀបចំផ្តល់ទីកន្លែងសម្រាប់អ្នកលក់ដូរតូចតាចតាមចិញ្ចើមផ្លូវ ហើយផ្តល់នូវតម្លៃធូរថ្លៃរួមមាន តាមផ្សារ តាមឆ្នេរ និងតំបន់ទេសចរណ៍ |
| តម្រូវការទី ១៣ | ពង្រឹងគុណភាពនៃការបង្រៀនក្នុងម៉ោងរដ្ឋ បង្កើនចំនួនអាហារូបករណ៍សម្រាប់ជំនាញសិក្សាថ្នាក់ឧត្តមសិក្សា និងកន្លែងស្នាក់នៅឥតគិតថ្លៃ ជាពិសេសស្ត្រី |
| តម្រូវការទី ១៤ | រាជរដ្ឋាភិបាលផ្តល់សេវាជួយដល់ស្ត្រី ពិសេសស្ត្រីមានពិការភាពក្នុងការទទួលសេវាគាំពារផ្នែកសុខភាព ផ្លូវចិត្ត និងផ្លូវច្បាប់ |
| តម្រូវការទី ១៥ | ធ្វើវិសោធនកម្មច្បាប់ និងប្រកាសបេឡាជាតិរបបសន្តិសុខសង្គមដោយកែសម្រួលលក្ខខណ្ឌ តម្រូវឱ្យនិយោជកនៃសហគ្រាសនោះបានបង់ប្រាក់ភាគទាន ៩ខែជាប់លាប់ ទើបកម្មករជាស្ត្រីមានផ្ទៃពោះទទួលបានប្រាក់ឧបត្ថម្ភ ៧០ភាគរយនៃប្រាក់ជាប់ភាគទាន |
| តម្រូវការទី ១៦ | ពង្រីកទីផ្សារការងារក្នុងស្រុកបង្កើនជំនាញថ្មី រួមទាំងពន្លឿនការអនុវត្តគោលនយោបាយផ្តល់ប្រាក់ឧបត្ថម្ភ អំឡុងពេលបាត់បង់ប្រាក់ចំណូល ឬអត់ការងារធ្វើ ជាពិសេសសម្រាប់ស្ត្រី និងយុវជន |
| តម្រូវការទី ១៧ | ពន្លឿនការចុះបញ្ជីពលរដ្ឋដែលធ្វើការក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ តាមរយៈនិរាករណ៍ប្រកាសអន្តរក្រសួង៤០៤ |

យើងខ្ញុំសូមធ្វើការបរិយាយសេចក្តីលម្អិតពីតម្រូវការ និងយន្តការដោះស្រាយជាក់លាក់របស់ស្ត្រីដាក់ជូនអ្នកតាក់តែងគោលនយោបាយធ្វើការដោះស្រាយជាអាទិភាព និងបន្ទាន់ដើម្បីធានាបាននូវសមភាពយេនឌ័រ កាត់បន្ថយគម្លាតរវាងអ្នកមាន និងអ្នកក្រ និងធានាបាននូវការពារដល់សុខមាលរបស់ប្រជាពលរដ្ឋ៖



# តម្រូវការទី១

## បង្កើតមត្តេយ្យសហគមន៍ និង ទារកដ្ឋាននៅតាមកន្លែងការងារ

### បញ្ហាដែលកើតមានឡើង៖

- ស្ត្រីជនបទ កម្មករស្ត្រី និងស្ត្រីប្រកបរបរសេដ្ឋកិច្ចក្រៅប្រព័ន្ធជួបនូវបញ្ហាលំបាកពេលលក់ដូរតាមដងផ្លូវ និងបំពេញការងារ។ ពួកគាត់ត្រូវដាក់កូនតាមរទេះរុញ កណ្តៀតកូនបណ្តើរ ធ្វើការងារបណ្តើរ ត្រូវផ្ញើកូនជាមួយអ្នកជិតខាង និងត្រូវទុកកូនតូចឱ្យនៅផ្ទះម្នាក់ឯង ឬទុកជាមួយឪពុកម្តាយចាស់ជរាដែលធ្វើឱ្យប៉ះពាល់ដល់សុវត្ថិភាព សុខភាព និងការលូតលាស់របស់កុមារ។
- យោងតាមច្បាប់ការងារ មាត្រា១៨៦ តម្រូវឱ្យនិយោជកដែលជួលកម្មករស្ត្រីចាប់ពី ១០០ នាក់ឡើង បង្កើតទារកដ្ឋាន ប៉ុន្តែកន្លែងធ្វើការភាគច្រើនមិនទាន់បានបង្កើតទារកដ្ឋានទេ។

### ដំណោះស្រាយ៖

- ស្នើក្រសួងការងារដាក់កំហិតឱ្យគ្រប់គ្រឹះស្ថានការងារដែលបានជួលកម្មករនិយោជិកចាប់ពី ១០០ នាក់ឡើង សាងសង់ទារកដ្ឋានដែលមានគុណភាព។
- ស្នើក្រសួងការងារ និងក្រសួងអប់រំ យុវជន និងកីឡា បង្កើតឱ្យមានទារកដ្ឋានសម្រាប់ក្មេងអាយុចាប់ពី១៨ខែឡើង និងបង្កើត និងពង្រីកមត្តេយ្យសហគមន៍នៅគ្រប់ឃុំ/សង្កាត់ដោយគិតគូឱ្យបានគ្រប់ជ្រុងជ្រោយលើគុណភាពជាចម្បង។



# តម្រូវការទី២

## ជម្រកសុវត្ថិភាពសម្រាប់ស្ត្រីដែលជួបបញ្ហាអំពើហិង្សាក្នុងគ្រួសារ និងសម្រាប់កម្មករស្ត្រីដែលធ្វើការងារតាមផ្ទះ និងកម្មករចំណាកស្រុក

### បញ្ហាដែលកើតមានឡើង៖

- នៅពេលដែលស្ត្រីរងអំពើហិង្សាក្នុងគ្រួសារ ឬកម្មករស្ត្រីធ្វើការងារតាមផ្ទះរងអំពើហិង្សាពីម្ចាស់ផ្ទះ ជនរងគ្រោះគ្មានលទ្ធភាពនៅឱ្យឆ្ងាយពីជនបង្ក និងមិនមានជម្រកសុវត្ថិភាពដើម្បីការពារជន រងគ្រោះ ដែលជាហេតុធ្វើឱ្យជនបង្កនៅតែមានឱកាសរំខាន បន្តប្រើហិង្សា និងគំរាមកំហែងដល់ជនរងគ្រោះ។
- អាជ្ញាធរមូលដ្ឋានខ្វះចន្លោះនូវការអនុវត្តតាមនីតិវិធី ដោយកន្លងមកបានធ្វើកិច្ចអន្តរាគមន៍ឱ្យស្ត្រីយោគយល់ អត់ឱន ផ្តល់ឱកាសឱ្យជនបង្ក និងឱ្យស្ត្រីកែប្រែឥរិយាបថដើម្បីចៀសវាងជម្លោះ។

### ដំណោះស្រាយ៖

- រាជរដ្ឋាភិបាលជំរុញឱ្យមានការបង្កើតមជ្ឈមណ្ឌលផ្តល់សេវាកម្មគ្រប់ប្រភេទនៅកន្លែងតែមួយសម្រាប់ជនរងគ្រោះអំពើហិង្សាដោយផ្អែកលើយែនឌ័រ។ សេវាកម្មដែលផ្តល់ឱ្យត្រូវប្រកបដោយគុណភាពដែលរួមមានការប្រឹក្សាផ្លូវចិត្ត ការប្រឹក្សា និងការគាំពារផ្លូវច្បាប់ ការព្យាបាលសុខភាពរាងកាយ ការផ្តល់ជម្រកសុវត្ថិភាព និងការការពារសន្តិសុខដល់ស្ត្រីរងគ្រោះ និងកូនៗផងដែរ។
- រាជរដ្ឋាភិបាលជំរុញឱ្យមានប្រព័ន្ធរាយការណ៍តាមទូរស័ព្ទដែលជនរងគ្រោះ ឬសាក្សីដែលបានឃើញហេតុការណ៍អាចរាយការណ៍អំពីហេតុការណ៍នោះ ដោយគ្មានការភ័យខ្លាច និងធានាបាននូវការសម្ងាត់អំពីអត្តសញ្ញាណរបស់អ្នករាយការណ៍។ មន្ត្រីទទួលព័ត៌មាននេះត្រូវមានជំនាញត្រឹមត្រូវ និងធ្វើការណែនាំភ្លាមៗទៅកាន់សេវាកម្មពាក់ព័ន្ធ។
- អាជ្ញាធរត្រូវមានតួនាទីផ្តល់ការគាំទ្រឱ្យជនរងគ្រោះមានលទ្ធភាពដាក់ពាក្យបណ្តឹងទៅតុលាការ និងមានសិទ្ធិសុំដីកាការពារ។

# តម្រូវការទី៣

## ចាត់វិធានការឱ្យមានប្រសិទ្ធភាព ចំពោះអំពើហិង្សា និងការបៀតបៀនគ្រប់ទម្រង់មកលើស្ត្រី ដោយគ្មានការលើកលែង



### បញ្ហាដែលកើតមានឡើង៖

- ស្ត្រីនៅក្នុងសេវាកំសាន្ត ម៉ាស្សា ផ្សព្វផ្សាយស្រាបៀរ កាស៊ីណូ និងអ្នករៀបបន្ទប់តាមផ្ទះសំណាក់ ឬសណ្ឋាគារ ប្រឈមនូវការបៀតបៀនរាងកាយ ការចាប់បង្ខំ និងហិង្សាផ្លូវភេទ ពីសំណាក់អតិថិជន អ្នកគ្រប់គ្រង ឬថៅកែហើយកន្លងមកមិនមានដំណោះស្រាយក្រៅពីឱ្យកម្មករទ្រាំបន្តទទួលយកនូវអំពើហិង្សានោះ បើមិនដូច្នោះត្រូវបញ្ឈប់ពីការងារ។
- កន្លងមកជនបង្កបានទទួលទោសពិន័យដោយគ្រាន់តែជាការទូទាត់សំណងរដ្ឋប្បវេណីទៅឱ្យជនរងគ្រោះដើម្បីជាថ្នូរនិងការបញ្ចប់រឿង ហើយតែងតែរួចខ្លួនលើករណីព្រហ្មទណ្ឌដែលបង្ហាញពីកំសោយនៃការអនុវត្តច្បាប់ និងជំរុញឱ្យអំពើហិង្សាលើស្ត្រីកើតមានជាបន្តបន្ទាប់។
- មានលក្ខខណ្ឌជាសំងាត់ដែលបានកំពុង និងកើតមានឡើងនៅក្នុងមជ្ឈមណ្ឌល ឬគ្រឹះស្ថានកំសាន្ត ខារ៉ាអូខេ ពីសំណាក់អ្នកគ្រប់គ្រង និងនិយោជកដោយតម្រូវឱ្យកម្មករនិយោជិកជាស្ត្រីធ្វើតេស្តរកមើលថាមានផ្ទៃពោះ ឬអត់ និងដាក់លក្ខខណ្ឌឱ្យរំលូតកូន ឬត្រូវបណ្តេញចេញពីការងារ។
- បើទោះក្នុងច្បាប់ស្តីពីការងារបានចែងអំពីកាតព្វកិច្ចរបស់និយោជកក្នុងការចុះបញ្ជីបេឡាជាតិរបបសន្តិសុខសង្គមលើគ្រោះថ្នាក់ការងារ ការថែទាំសុខភាព និងប្រាក់សោធននិវត្តន៍ តែនិយោជកភាគច្រើននៅក្នុងវិស័យសេវាកំសាន្តនេះមិនបានអនុវត្តទៅតាមច្បាប់នៅឡើយ។
- ក្រោយពីកូវីដ១៩ បានបញ្ចប់កម្មករនៅក្នុងវិស័យសេវាកម្សាន្តប្រែក្លាយជាកម្មករមិនមានប្រាក់ឈ្នួលគោល មិនមានការងារទៀងទាត់ ហើយធ្វើការច្រើនម៉ោងដោយមិនមានការទូទាត់ប្រាក់សំណងលើការងារថែមម៉ោងនោះឡើយ។

- និយោជកមិនអន្តរាគមន៍ ហើយអាជ្ញាធរចាត់ទុកថាជារឿងធម្មតា អំពើហិង្សា ការបៀតបៀនពីអតិថិជនមកលើស្ត្រីដែលធ្វើការនៅសេវាកម្មកម្សាន្ត ។
- ករណីអំពើហិង្សាមានស្ថានភាពធ្ងន់ធ្ងររហូតដល់កម្មករមិនអាចទទួលយកបាន ក៏ការដោះស្រាយគឺបានត្រឹមតែសម្របសម្រួលបញ្ចប់ដោយការផ្តល់ប្រាក់ជំងឺបន្តិចបន្តួច ចំណែកជនល្មើសមិនត្រូវបានឱ្យទទួលខុសត្រូវចំពោះមុខច្បាប់ឡើយ។

## ដំណោះស្រាយ៖

- រាជរដ្ឋាភិបាលត្រូវមានគោលនយោបាយតម្រូវឱ្យគ្រប់គ្រឹះស្ថានសេវាកំសាន្តបង្កើតនូវគោលនយោបាយប្រឆាំងអំពើបៀតបៀន និងអំពើហិង្សាគ្រប់រូបភាពមកលើស្ត្រី ដោយគិតពីសិទ្ធិ សុខុមាលភាព និងសេចក្តីថ្លៃថ្នូររបស់កម្មករនិយោជិកមុនប្រាក់ចំណេញ។
- ក្រុមការងារអន្តរក្រសួងទទួលបន្ទុកលើសុខភាព និងសុវត្ថិភាពនៅកន្លែងការងារត្រូវធ្វើការត្រួតពិនិត្យតាមដានធានាថា គ្រប់គ្រឹះស្ថានមានគោលនយោបាយប្រឆាំងអំពើបៀតបៀន និងអំពើហិង្សាគ្រប់រូបភាពមកលើកម្មករស្ត្រី និងអន្តរាគមន៍ជាបន្ទាន់ជំរុញឱ្យនិយោជកអនុវត្តគោលនយោបាយនោះប្រកបដោយប្រសិទ្ធភាព។
- បេឡាជាតិរបបសន្តិសុខសង្គមជំរុញឲ្យម្ចាស់គ្រឹះស្ថាន ឬសហគ្រាសសេវាកំសាន្ត ជាពិសេសផ្នែកខារ៉ាអូខេ និងម៉ាស្សាអនុវត្តការចុះបញ្ជីនៅបេឡាជាតិរបបសន្តិសុខសង្គមសម្រាប់កម្មករនិយោជិក។
- អធិការកិច្ចការងារត្រូវចុះត្រួតពិនិត្យ និងតាមដានគ្រប់គ្រឹះស្ថាន ឬសហគ្រាសសេវាកំសាន្តដើម្បីធានានូវការការពារគ្មានលក្ខខណ្ឌរំលូតកូនដោយបង្ខំ និងការបណ្តេញចេញពីការងារដោយការរើសអើងលើស្ត្រីមានផ្ទៃពោះ ព្រមទាំង មានការដាក់ទោសទណ្ឌដល់និយោជកណាដែលបានប្រព្រឹត្តមកលើកម្មករនិយោជិកស្ត្រីក្នុងលក្ខខណ្ឌបែបនេះ។
- បង្កើតឱ្យបាននូវយន្តការច្បាស់លាស់អំពីការការពារកម្មករនិយោជិកពីអំពើហិង្សា និងការបៀតបៀននៅតាមក្រុមហ៊ុន រោងចក្រ សហគ្រាសដោយមានការចូលរួមពីតំណាងកម្មករនិយោជិក និងនិយោជក។
- រដ្ឋាភិបាលត្រូវប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយឱ្យបានទូលាយអំពីយន្តការនានាដែលជួយគាំទ្រពេលមានករណីមានការរំលោភបំពាន និងចាប់ជនល្មើសឱ្យទទួលខុសត្រូវទាំងរដ្ឋប្បវេណី និងទោសព្រហ្មទណ្ឌ។
- រដ្ឋាភិបាលផ្តល់សច្ចាប័នលើអនុសញ្ញាលេខ ១៩០ ស្តីពីការលុបបំបាត់អំពើហិង្សា និងការបៀតបៀននៅក្នុងពិភពការងារដែលគ្របដណ្តប់ដល់កម្មករនិយោជិកគ្រប់ប្រភេទ គ្រប់វិស័យ រួមទាំងនៅក្នុងសហគមន៍។

# តម្រូវការទី៤

## ចាត់វិធានារដ្ឋបាលជាក់លាក់ និងបញ្ឈប់ការប្រើប្រាស់អំពើហិង្សាលើស្ត្រី អ្នកការពារសិទ្ធិមនុស្ស សិទ្ធិដីធ្លី បរិស្ថាន និងសិទ្ធិការងារ



**បញ្ហាដែលកើតមានឡើង៖**

- កន្លងមកអាជ្ញាធរមូលដ្ឋានភាគច្រើនខ្វះការយកចិត្តទុកដាក់បង្កើតឱកាសឱ្យភាគីពាក់ព័ន្ធបានជួបពិភាក្សារកដំណោះស្រាយសមស្រប និងទាន់ពេលវេលា ព្រមទាំងមានការគម្រាមកំហែង និងការប្រើអំពើហិង្សាលើរាងកាយ និងស្មារតីទៅលើស្ត្រីសកម្មជនសិទ្ធិមនុស្សក្នុងចេតនារាំងមិនឱ្យមានការជួបជុំ និងដើរក្បួននៅទីសាធារណៈដើម្បីទាមទាររកយុត្តិធម៌លើបញ្ហារបស់ពួកគេ។
- មានការប្រើប្រាស់ប្រព័ន្ធតុលាការជាឧបករណ៍ដើម្បីដាក់សម្ពាធ និងបំបិទសម្លេងរបស់ស្ត្រី សកម្មជនសិទ្ធិមនុស្ស តាមរយៈការដាក់ឱ្យនៅក្រោមការត្រួតពិនិត្យរបស់តុលាការ ឬចោទប្រកាន់ពីបទបរិហារកេរ្តិ៍ និងបទបំផ្លិចបំផ្លាញលើទ្រព្យសម្បត្តិឯកជន និងការចាប់ខ្លួនស្ត្រីជាដើម។
- មានការកើនឡើងជាច្រើនករណីចោទប្រកាន់បទព្រហ្មទណ្ឌប្រឆាំងថ្នាក់ដឹកនាំសហជីពដែលអនុវត្តតួនាទី និងសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិតាមរយៈការធ្វើកូដកម្មដោយសន្តិវិធីបន្ទាប់ពីច្បាប់សហជីពត្រូវបានអនុម័តកាលពីឆ្នាំ២០១៦។
- នៅរាល់ពេលដែលមានការផ្ទុះការតវ៉ារបស់កម្មករនិយោជិកប្រឆាំងនឹងការរំលោភបំពានពីសំណាក់ថៅកែ តំណាងសហជីពតែងត្រូវបានចោទប្រកាន់ថាបានញុះញង់កម្មករ រហូតដល់មានករណីខ្លះឈានដល់ការឃុំខ្លួនដូចករណីកូដកម្មនៅក្រុមហ៊ុនណាហ្គាវើលដ៍ថ្នាក់ដឹកនាំសហជីពចំនួន៨រូបត្រូវបានឃុំខ្លួន និងកាស៊ីណូមួយចំនួនទៀតនៅកំពង់សោមជាដើម។
- ច្បាប់កូវីដ១៩ ក៏ត្រូវបានប្រើដើម្បីចោទប្រកាន់កម្មករដែលចូលរួមកូដកម្មផងដែរ ជាលទ្ធផលកូដករក្រុមហ៊ុនណាហ្គាវើលដ៍ត្រូវបានចាប់ដាក់ពន្ធធាគារកាលពីដើមខែកុម្ភៈ ឆ្នាំ២០២២ កន្លងមក។

- បើទោះបីជាក្នុងច្បាប់ជាតិ និងច្បាប់អន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាផ្តល់សច្ចាប័ន មានចែងពីការការពារ តំណាងសហជីពពីការរើសអើងដោយការយកហេតុផលសហជីពដើម្បីបញ្ឈប់ពីការងារ ប៉ុន្តែនិយោជកតែងបញ្ឈប់តំណាងសហជីពបានតាមអំពើចិត្តជាពិសេសនៅក្នុងវិបត្តិកូវីដ១៩។

## ដំណោះស្រាយ៖

- រាជរដ្ឋាភិបាលជំរុញឱ្យមានការអនុវត្តន៍ច្បាប់ដាច់ខាតដែលអនុលោមទៅតាមគោលការណ៍សិទ្ធិមនុស្សជាសកល និងលើកកម្ពស់សិទ្ធិសេរីភាពជាមូលដ្ឋានដូចជា សិទ្ធិបញ្ចេញមតិ សិទ្ធិជួបប្រជុំ សិទ្ធិក្នុងការចងក្រងសហជីព សិទ្ធិចូលរួម និងសិទ្ធិបង្កើតអង្គការសមាគមដោយគ្មានការយាយីរំខាន ការឃ្លាំមើល និងការជ្រៀតជ្រែកពីសំណាក់អាជ្ញាធរ ឬមន្ត្រីមានសមត្ថកិច្ច។
- តុលាការត្រូវធានានូវឯករាជ្យភាព ស្របតាមស្មារតីរដ្ឋធម្មនុញ្ញ ជាពិសេសមិនឈរលើអគតិទាំង៤ ដែលតែងតែដាស់តឿនសតិ និងការបម្រើតួនាទីដោយសុចរិតភាព ស្មោះត្រង់ចំពោះមុខងាររបស់ខ្លួនដូចដែលបានធ្វើសច្ចាប្រណិធានមុនចូលកាន់តួនាទីនេះ។
- រាជរដ្ឋាភិបាលត្រូវធានានូវសិទ្ធិសេរីភាពក្នុងការសម្តែងមតិតាមរយៈការធ្វើកូដកម្មដោយសន្តិវិធី។ ទម្លាក់ចោលបទចោទប្រកាន់ប្រឆាំងថ្នាក់ដឹកនាំសហជីពទាំងអស់ និងរាជរដ្ឋាភិបាលត្រូវអនុវត្តតាមស្មារតីអនុសញ្ញាស្នូលអង្គការអន្តរជាតិខាងការងារ ILO C87 និង C98 ដែលកម្ពុជាផ្តល់សច្ចាប័នដែលធានាសិទ្ធិក្នុងការបង្កើតសហជីព សិទ្ធិក្នុងការចរចាជាសមូហភាព និងសិទ្ធិក្នុងការធ្វើកូដកម្ម។
- ច្បាប់ទាំងឡាយណាដែលបង្កើតឡើងផ្ទុយពីស្មារតីរដ្ឋធម្មនុញ្ញបង្កឱ្យមានភាពអយុត្តិធម៌រាជរដ្ឋាភិបាលត្រូវលុបចោល ជំនួសមកវិញនូវច្បាប់ដែលផ្តល់ភាពយុត្តិធម៌ក្នុងសង្គម។





# តម្រូវការទី៥

## កំណែទម្រង់មធ្យោបាយដឹកជញ្ជូនកម្មករក្នុងវិស័យវាយនភ័ណ្ឌ កាត់ដេរ និងដេរស្បែកជើង

**បញ្ហាដែលកើតមានឡើង៖**

- កន្លងមកឡានដឹកកម្មករនិយោជិកតែងតែរងគ្រោះថ្នាក់អំឡុងពេលធ្វើដំណើរ ដោយឡានទាំងនោះមិនមានការត្រួតពិនិត្យលក្ខណៈបច្ចេកទេសអោយបានត្រឹមត្រូវ មិនមានកន្លែងអង្គុយដែលមានសុវត្ថិភាព កម្មករត្រូវឈរប្រជ្រៀតគ្នា និងអ្នកបើកបរឡានមានប្រើគ្រឿងស្រវឹង។
- របាយការណ៍របបបេឡាសន្តិសុខសង្គមបានឱ្យដឹងថា មានកម្មករចំនួន៥៦៣នាក់រងរបួស និងស្លាប់១០នាក់ គិតត្រឹមឆមាសទី១ ឆ្នាំ២០១៨។ របាយការណ៍នេះក៏បានបង្ហាញដែរថាប្រហែល២០ភាគរយនៃអ្នកបើកបររថយន្តដឹកកម្មករក្នុងវិស័យកាត់ដេរមិនមានអាជ្ញាប័ណ្ណ។

**ដំណោះស្រាយ៖**

- រាជរដ្ឋាភិបាលត្រូវបង្កើតគោលនយោបាយស្តីពីការដឹកជញ្ជូនកម្មករនិយោជិកក្នុងវិស័យវាយនភ័ណ្ឌ កាត់ដេរ និងដេរស្បែកជើងដោយកំណត់ពីការរៀបចំឡានដឹកជញ្ជូនកម្មករដែលធានានូវផាសុខភាព និងសុវត្ថិភាពសម្រាប់កម្មករ ឬតម្រូវឱ្យនិយោជកទទួលរ៉ាប់រងក្នុងការជ្រើសរើសសេវាដឹកជញ្ជូនដែលមានគុណភាពសម្រាប់ផ្តល់ឱ្យកម្មករ។



# តម្រូវការទី៦

## កែលម្អលក្ខខណ្ឌការងារ និងពង្រឹងយន្តការការពារអ្នកធ្វើការងារតាមផ្ទះ

### បញ្ហាដែលកើតមានឡើង៖

- ចំនួនអ្នកធ្វើការងារតាមផ្ទះនៅក្នុងប្រទេសកម្ពុជាមានច្រើនប្រមាណ២៥០,០០០នាក់ ហើយភាគច្រើនជាស្ត្រី ដោយឡែកច្បាប់ស្តីពីការងារមិនបានដាក់បញ្ចូលអ្នកធ្វើការងារតាមផ្ទះឡើយ។
- បើទោះបីក្រសួងការងារបានចេញប្រកាសលេខ២៣៥ កាលពីថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៨ ស្តីពីលក្ខខណ្ឌការងារសម្រាប់អ្នកធ្វើការតាមផ្ទះ ប្រការ១៣ បានចែងអំពីកាតព្វកិច្ចរបស់និយោជកក្នុងការចុះបញ្ជីរបបបេឡាជាតិសន្តិសុខសង្គមលើគ្រោះថ្នាក់ការងារ ការថែទាំសុខភាព និងប្រាក់សោធននិវត្តន៍ តែម្ចាស់ផ្ទះភាគច្រើន មិនទាន់បានអនុវត្តទៅតាមប្រកាសនេះនៅឡើយ។ ម្យ៉ាងទៀតប្រកាសនេះនៅមានចំនុចខ្វះខាតមួយចំនួនទៀតដោយមិនទាន់បានបញ្ជាក់ពីប្រាក់ខែគោល កិច្ចសន្យាការងាររវាងម្ចាស់ផ្ទះ និងកម្មករ និងមិនបានដាក់បញ្ចូលនូវការឈប់សម្រាកលំហែមាតុភាពដោយមានប្រាក់ឈ្នួល និងសម្រាកបុណ្យជាតិផ្សេងៗ។

### ដំណោះស្រាយ៖

- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈជំរុញនិយោជកឱ្យចុះបញ្ជីរបបបេឡាជាតិសន្តិសុខសង្គមសម្រាប់កម្មករអ្នកធ្វើការតាមផ្ទះយោងតាមប្រកាស២៣៥ ស្តីពីលក្ខខណ្ឌការងារអ្នកធ្វើការងារតាមផ្ទះចេញដោយក្រសួងការងារ ប្រការ១៣។
- ស្នើឱ្យក្រសួងការងារបង្កើតកិច្ចសន្យាគំរូជាលាយល័ក្ខអក្សររវាងម្ចាស់ផ្ទះជាមួយអ្នកធ្វើការតាមផ្ទះដែលស្របទៅតាមលក្ខខណ្ឌការងារ ការគោរពសិទ្ធិការងារ និងការការពារ រួមទាំងអត្ថប្រយោជន៍ផ្សេងៗ។
- ក្រសួងការងារកំណត់ប្រាក់ឈ្នួលអប្បរមាសម្រាប់អ្នកធ្វើការតាមផ្ទះ។
- ស្នើរាជរដ្ឋាភិបាលផ្តល់សច្ចាប័នអនុសញ្ញា ILO 189 ស្តីពីការការពារកម្មករធ្វើការងារតាមផ្ទះដើម្បីកម្មករធ្វើការងារតាមផ្ទះទាំងក្នុង និងក្រៅប្រទេសទទួលបាននូវការការពារសិទ្ធិ និងផលប្រយោជន៍ផ្សេងៗ។

# តម្រូវការទី៧

## ពង្រឹងយន្តការការពារសិទ្ធិពលករចំណាកស្រុកពីការកេងប្រវ័ញ្ចពលកម្ម ការជួញដូរមនុស្ស និងទាសភាពសម័យទំនើប



### បញ្ហាដែលកើតមានឡើង៖

- ការធ្វើចំណាកស្រុកស្វែងរកការងារធ្វើនៅក្រៅប្រទេសគឺជាសិទ្ធិ និងជម្រើសរបស់បុគ្គលម្នាក់ៗ ប៉ុន្តែតាមរយៈការសិក្សាកន្លងមកបង្ហាញថា ពលករកម្ពុជាភាគច្រើនបង្ខំចិត្តធ្វើចំណាកស្រុកដោយកត្តាជីវភាព ការជំពាក់បំណុល ពុំមានការងារធ្វើក្នុងស្រុក និងតម្លៃទិន្នផលកសិកម្មធ្លាក់ចុះជាដើម។ កត្តានេះនាំឱ្យការធ្វើចំណាកស្រុករបស់ពួកគេមានភាពប្រថុយប្រថាន ងាយចាញ់បោកមេខ្យល់ឆ្លងដែនដោយពុំមានឯកសារគ្រប់គ្រាន់ និងត្រូវចាប់ខ្លួនដោយអាជ្ញាធរនៅប្រទេសគោលដៅ។ គិតត្រឹមដើមឆ្នាំ២០២២ មកដល់ពេលនេះ មានពលរដ្ឋកម្ពុជាចំនួន២,១២១នាក់ឆ្លងដែនដោយខុសច្បាប់ទៅរកការងារធ្វើនៅប្រទេសថៃ ក្នុងនោះច្រើនជាង៤០%ជាស្ត្រី និងកុមារតូចៗ។
- របាយការណ៍របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបង្ហាញថាមានពលករកម្ពុជាចំនួន ១,៣០១,៦០៩នាក់កំពុងបម្រើការងារក្នុងប្រទេសគោលដៅចំនួន៧ រួមមានប្រទេស ថៃ ម៉ាឡេស៊ី សឹង្ហបុរី ជប៉ុន កូរ៉េខាងត្បូង អារ៉ាប៊ីសាអូឌីត និងហុងកុង។ ប៉ុន្តែ តួលេខនេះមិនបានឆ្លុះបញ្ចាំងពីភាពជាក់ស្តែងនៃពលករកម្ពុជាដែលចំណាកស្រុកតាមផ្លូវមិនប្រក្រតី ឬដោយមិនមានឯកសារស្របច្បាប់នោះទេ។ កង្វះខាតទិន្នន័យ និងព័ត៌មានមិនគ្រប់គ្រាន់អាចធ្វើឱ្យការឆ្លើយតបរបស់អាជ្ញាធរទៅនឹងតម្រូវការ និងបញ្ហាប្រឈមរបស់ពលករចំណាកស្រុកមិនបានគ្រប់ជ្រុងជ្រោយ និងមិនទាន់មានប្រសិទ្ធភាពខ្ពស់។
- មានការកើនឡើងគួរអោយកត់សម្គាល់នូវទម្រង់នៃការរើសអើង ការរំលោភបំពានសិទ្ធិការងារ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម អំពើហិង្សាផ្អែកយេនឌ័រ និងបញ្ហាផ្សេងៗ មកលើក្រុមពលករចំណាកស្រុក ពិសេសអ្នកដែលមិនមានឯកសារស្របច្បាប់ និងពលករជាស្ត្រី។ ពលករស្ត្រីដែលធ្វើការក្នុងវិស័យសំណង់ ស្ត្រីមានផ្ទៃពោះត្រូវបានថៅកែបញ្ឈប់ការងារមិនបើកប្រាក់ឈ្នួល ឬធ្វើការទទួលបានប្រាក់ឈ្នួលតិច និងមិនទាន់ទទួលបានគាំទ្រពេញលេញក្នុងកិច្ចគាំពារសង្គមនៅឡើយ។

- ពលករស្ត្រីដែលបម្រើការងារតាមផ្ទះរិញរឹតតែប្រឈមនឹងបញ្ហាកាន់តែធ្ងន់ ពិសេសគឺពលកម្មដោយបង្ខំ ការដកហូតឯកសារ ការរំលោភសិទ្ធិការងារ អំពើហឹង្សាលើរូបរាងកាយ ការរំលោភបំពានផ្លូវភេទ ការប៉ះពាល់ផ្លូវចិត្ត ព្រមទាំងមិនអាចស្វែងរកជំនួយអន្តរាគមន៍ផ្លូវច្បាប់បានទាន់ពេលវេលា។ លើសពីនេះទៅទៀត អំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចកម្លាំងពលកម្មមានសភាពប្រែប្រួល និងវិវត្តទៅរកទម្រង់ថ្មីដោយមេខ្យល់ធ្វើការងារជាបណ្តាញ និងប្រើប្រាស់ប្រព័ន្ធសង្គមដើម្បីធ្វើការឆបោកលួងលោមជនរងគ្រោះដែលភាគច្រើនជាស្ត្រី និងកុមារដែលទន់ខ្សោយផ្នែកសេដ្ឋកិច្ចដើម្បីនាំឆ្លងដែនខុសច្បាប់ទៅចិន រៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។ល។

## ដំណោះស្រាយ៖

- រាជរដ្ឋាភិបាលកម្ពុជា ពិសេសក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងស្ថានទូតកម្ពុជាប្រចាំនៅប្រទេសគោលដៅត្រូវបង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យអំពីចំនួនពលករកម្ពុជា ពិសេសពលករជាស្ត្រីដែលធ្វើការនៅប្រទេសគោលដៅ ដូចជានៅប្រទេសថៃ ម៉ាឡេស៊ី។ ទិន្នន័យដែលត្រឹមត្រូវ និងគ្រប់ជ្រុងជ្រោយអំពីចំនួនពលករទៅតាមវិស័យការងារ អាស័យដ្ឋានកន្លែងធ្វើការ និងកន្លែងស្នាក់នៅរបស់ពលករអាចជួយឱ្យការអន្តរាគមន៍មានភាពឆាប់រហ័ស និងប្រសិទ្ធភាពខ្ពស់នៅពេលដែលពលករមានបញ្ហា។
- សិទ្ធិសេរីភាពជាមូលដ្ឋានរបស់ពលករចំណាកស្រុក សិទ្ធិក្នុងការជួបជុំ សេរីភាពក្នុងការបញ្ចេញមតិគួរត្រូវបានធានាការពារ ហើយរាល់សកម្មភាពទាំងឡាយដែលជ្រៀតជ្រែក ឬគម្រាមកំហែងទៅដល់សេរីភាពក្នុងការបញ្ចេញមតិ និងការជួបប្រជុំរបស់ពលករត្រូវបញ្ឈប់ជាបន្ទាន់។
- រាជរដ្ឋាភិបាលត្រូវបង្កើតគណកម្មការចុះតាមដាន និងវាយតម្លៃទៅលើដំណើរការបញ្ជូនពលករនៅប្រទេសទទួលប្រចាំត្រីមាសដើម្បីធានាបានថាអនុស្សារណៈរវាងរដ្ឋ និងរដ្ឋនោះពិតជាបានអនុវត្តត្រឹមត្រូវ ជាពិសេសពលករស្ត្រីបម្រើការងារតាមផ្ទះទទួលបាននូវការគោរពសិទ្ធិសេរីភាពជាមូលដ្ឋាន ការគាំពារសង្គម ព្រមទាំងសិទ្ធិកាន់កាប់ឯកសារផ្ទាល់ខ្លួន។ល។
- ស្ថានទូត ស្ថានកុងស៊ុលត្រូវបង្កើតមណ្ឌលសុវត្ថិភាពដើម្បីផ្តល់ការឆ្លើយតបបន្ទាន់ និងចាំបាច់នានាដល់ពលករដែលជួបបញ្ហា ពិសេសជនរងគ្រោះដោយអំពើជួញដូរមនុស្ស រួមមានការផ្គត់ផ្គង់អាហារ កន្លែងស្នាក់អាស្រ័យបណ្តោះអាសន្នដែលមានសុវត្ថិភាព ផ្តល់សេវាប្រឹក្សាយោបល់ និងជំនួយគាំពាផ្លូវច្បាប់ជាដើម។
- ពង្រឹងកិច្ចសហការជាមួយអាជ្ញាធរក្នុងប្រទេសគោលដៅ និងភាគីពាក់ព័ន្ធក្នុងការទប់ស្កាត់ បង្ក្រាបបទល្មើស និងផ្តន្ទាទោសមេខ្យល់នៃអំពើជួញដូរមនុស្ស ការនាំឆ្លងដែនខុសច្បាប់ អាពាហ៍ពិពាហ៍ផ្ទុយពីឆន្ទៈ (ពិសេសករណីទៅប្រទេសចិន)។

# ករណីសិក្សាទី៨

ពង្រឹង និងពង្រីកវិសាលភាពនៃប័ណ្ណសមាជិក ប.ស.ស. តាមរយៈការចុះធ្វើអធិការកិច្ច និងជំរុញឱ្យមានការចុះបញ្ជី និងបង់ភាគទាន ប.ស.ស. ក្នុងចំណោមនិយោជក ជាពិសេសគឺកម្មករនៅក្នុងវិស័យសំណង់ និងរោងចក្រ កាត់ដេរ វាយនភ័ណ្ឌដែលធ្វើការស៊ីឈ្នួលដេរបន្ត (Sub-Contract)




## បញ្ហាដែលកើតមានឡើង៖

- រោងចក្រប្រភេទស៊ីឈ្នួលដេរបន្ត (sub-contract factories) មានការកើនឡើងជាបន្តបន្ទាប់ និងមិនបានធ្វើការចុះញ្ជីក្នុងបេឡាជាតិរបបសន្តិសុខសង្គមដែលធ្វើឱ្យកម្មករនិយោជិក (ជាពិសេសកម្មករដែលជាស្ត្រី) បាត់បង់ការទទួលបានការការពារ និងអត្ថប្រយោជន៍ផ្សេងៗដែលផ្ដល់ជូនដោយច្បាប់ក្រោមបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស.)។
- ការរើសអើងប្រឆាំងនឹងកម្មករនិយោជនជាស្ត្រីដែលមានផ្ទៃពោះតាមរយៈការផ្ដល់កិច្ចសន្យាការងារខ្លី ឬមិនផ្ដល់កិច្ចសន្យាការងារថ្មីជូនពេលពួកគេត្រូវបានរកឃើញថាមានផ្ទៃពោះ។ ជាពិសេសទៀត រោងចក្រមិនបានផ្ដល់អត្ថប្រយោជន៍តាមច្បាប់ និងចុះបញ្ជីជាមួយ ប.ស.ស. ។ កត្តានេះ បានធ្វើឱ្យកម្មករនិយោជិកដែលជាស្ត្រីជាច្រើននាក់បានបាត់បង់សន្តិសុខប្រាក់ចំណូល បាត់បង់សិទ្ធិទទួលបានអត្ថប្រយោជន៍ផ្សេងៗតាមរយៈប័ណ្ណសមាជិក ប.ស.ស. និងអាចរុញពួកគេធ្លាក់ចូលទៅក្រោមបន្ទាត់នៃភាពក្រីក្រ និងវិសមភាពសង្គម។
- កម្មករនិយោជិកមួយចំនួនធំទទួលបានព័ត៌មាន ការបណ្ដុះបណ្ដាល និងចំណេះដឹងស្ដីពី ប.ស.ស. និងគោលនយោបាយកិច្ចគាំពារសង្គមតាមរយៈសហជីព។ ប៉ុន្តែការរើសអើងសកម្មភាពសហជីព (ឧ.ទា ការរារាំងសកម្មភាព ឬបញ្ឈប់មេដឹកនាំសហជីព) បានធ្វើឱ្យលទ្ធភាពទទួលបានអត្ថប្រយោជន៍ និងការការពារពី ប.ស.ស. ដើរថយក្រោយ ត្បិតការទទួលបានព័ត៌មាន និងចំណេះដឹងស្ដីពីរបបសន្តិសុខសង្គម ប.ស.ស. ក្នុងចំណោមកម្មករនិយោជិកនៅមានកម្រិត។

- ស្ថានភាពកម្មករដែលធ្វើការក្នុងប្រព័ន្ធទៅជាកម្មករក្រៅប្រព័ន្ធដោយសារពួកគាត់ត្រូវបានគេជួលឱ្យធ្វើការស៊ីថ្លៃ គ្មានសន្តិសុខការងារ គ្មានសន្តិសុខប្រាក់ចំណូល ការងារមានហានិភ័យខ្ពស់ ត្បិតកន្លែងធ្វើការគ្មានការត្រួតពិនិត្យប្រព័ន្ធសុខភាព និងសុវត្ថិភាពសម្រាប់កម្មករនិយោជន ជាពិសេសគឺមិនបានចុះបញ្ជី និងបង់វិភាគទានជាមួយបេឡាជាតិសន្តិសុខសង្គម ប.ស.ស.។

## ដំណោះស្រាយៈ

- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងពាណិជ្ជកម្ម និងរដ្ឋបាលថ្នាក់ក្រោមជាតិសហការគ្នាពង្រឹងការចែលរំលែកព័ត៌មាន និងការចុះធ្វើអធិការកិច្ចការងារ តាមរោងចក្រនានាដើម្បីកាត់បន្ថយរោងចក្រដែលស៊ីឈ្នួលដេរបន្ត និងដើម្បីជំរុញការបង់ភាគទានជូនកម្មករនិយោជិកទៅបេឡាជាតិសន្តិសុខសង្គម (ប.ស.ស.)។
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈធានាការគោរពសិទ្ធការងារ ជាពិសេសធានាការការពារចំពោះកម្មករនិយោជិកស្ត្រីដែលមានផ្ទៃពោះពីការរើសអើង និងបញ្ឈប់ពីការងារក្នុងកំឡុងពេលមានផ្ទៃពោះ និងក្រោយពេលសម្រាល។
- មន្ត្រីបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស.) និងរដ្ឋបាលថ្នាក់ក្រោមជាតិធ្វើការចុះអធិការកិច្ចចំពោះរោងចក្រស៊ីឈ្នួលបន្ត ហើយត្រូវដាក់ទោសយ៉ាងតឹងរឹងចំពោះរោងចក្រកាត់ដេរទាំងឡាយណាដែលមិនមានចុះបញ្ជីបេឡាជាតិរបបសន្តិសុខសង្គម។
- បេឡាជាតិរបបសន្តិសុខសង្គមធ្វើការគាំពារចំពោះកម្មករនិយោជកនៃសហគ្រាស ឬគ្រឹះស្ថាន រួមទាំងរោងចក្រដែលស៊ីឈ្នួលដេរបន្តមិនបានចុះបញ្ជី នៅពេលមានគ្រោះថ្នាក់ការងារ បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស.) ធ្វើការដាក់ទោសផាកពិន័យទៅលើម្ចាស់រោងចក្រនោះ តែកម្មករត្រូវទទួលបានការព្យាបាល ថែទាំ ស្របទៅតាមគោលនយោបាយរបស់បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស.)។



# គម្រូចការទី៩

## រាជរដ្ឋាភិបាលត្រូវធានាថាកម្មករក្នុងវិស័យសំណង់ និងឡឥដ្ឋមានសម្ភារៈសុខភាព សុវត្ថិភាព ត្រឹមត្រូវតាមច្បាប់ និងសហគ្រាស គ្រឹះស្ថាន បានចុះបញ្ជីជាសមាជិក ប.ស.ស



**បញ្ហាដែលកើតមានឡើង៖**

- មិនមានប្រព័ន្ធចុះត្រួតពិនិត្យតាមដានលក្ខខណ្ឌការងារ សុខភាព សុវត្ថិភាព របស់កម្មករក្នុងវិស័យសំណង់ និងឡឥដ្ឋ។
- កម្មករមួយចំនួនបានប្រើប្រាស់ថវិការផ្ទាល់ខ្លួនដើម្បីទិញសម្ភារៈការពារសុវត្ថិភាពរបស់ខ្លួន។
- ក្រុមអ្នកម៉ៅការបន្តមានការគេចវេសពីការទទួលខុសត្រូវ ពេលកម្មករមានគ្រោះថ្នាក់ការងារនៅកន្លែងការងារ។
- ពេលមានគ្រោះថ្នាក់ការងារ កម្មករប្រើប្រាស់ថវិកាផ្ទាល់ខ្លួនក្នុងការព្យាបាលជំងឺ។

**ដំណោះស្រាយ៖**

- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បង្កើនការចុះអធិការកិច្ចឱ្យបានញឹកញាប់នៅតាមបណ្តាការដ្ឋានសំណង់ និងសិប្បកម្មឡឥដ្ឋប្រកបដោយប្រសិទ្ធភាព។
- រាជរដ្ឋាភិបាលចេញប្រកាសស្តីពីសុខភាព សុវត្ថិភាពសម្រាប់កម្មករក្នុងវិស័យសំណង់។
- រាជរដ្ឋាភិបាលចេញប្រកាសស្តីពីការគ្រប់គ្រង និងអធិការកិច្ចលើក្រុមហ៊ុនម៉ៅការបន្ត។
- រាជរដ្ឋាភិបាលពន្លឿនការអនុវត្តន៍ចុះបញ្ជីប.ស.ស. ឱ្យបានឆាប់ និងមានប្រសិទ្ធភាពក្នុងវិស័យសំណង់។



# តម្រូវការទី១០

## ពង្រីកវិសាលភាពនៃប្រព័ន្ធគាំពារសង្គមឱ្យបានដល់សមាជិកគ្រួសារ

**បញ្ហាដែលកើតមានឡើង៖**

- ការអនុវត្តបច្ចុប្បន្ន កម្មករដែលធ្វើការងារចំពោះសហគ្រាស គ្រឹះស្ថានដែលបានចុះបញ្ជីជាសមាជិកបេឡាជាតិរបបសន្តិសុខសង្គមគឺទទួលបានការគាំពារចំពោះបុគ្គលខ្លួនឯងប៉ុណ្ណោះ។
- ពេលសមាជិកគ្រួសារដូចជា៖ ម្តាយ ឪពុក កូន និងស្វាមី-ភរិយា គឺមិនទទួលបានការគាំពារនោះឡើយ ដែលធ្វើឱ្យការស្វែងរកសេវាសុខភាពក្លាយជាបន្ទុក និងកត្តាជំពាក់បំណុលគ្រឹះស្ថានហិរញ្ញវត្ថុ និងអ្នកចងការប្រាក់ក្រៅប្រព័ន្ធ។ កត្តានេះបានធ្វើឱ្យការចំណាយដោយប្រាក់ហោប៉ៅលើសេវាសុខភាពមានកម្រិតខ្ពស់ដែលប៉ះពាល់ដល់លទ្ធភាពផ្តល់ការសិក្សា អាហាររូបត្ថម្ភ និងការវិនិយោគខ្នាតតូចសម្រាប់ក្រុមគ្រួសារ។



- ការពិនិត្យតាមដានសុខភាពមិនត្រូវបានដាក់បញ្ចូលក្នុងកម្មវិធីរបស់បេឡាជាតិ ប.ស.ស. នោះទេ។ ជាក់ស្តែង ការទៅទទួលសេវាសុខភាពគឺលុះត្រាណាតែសមាជិកប័ណ្ណ ប.ស.ស. ឈឺ ឬមានគ្រោះថ្នាក់ការងារ។ កត្តានេះហើយដែលធ្វើឱ្យលទ្ធភាពព្យាករណ៍រោគសញ្ញាជម្ងឺ (early detection) ក្នុងវិស័យវិជ្ជសាស្ត្រមិនត្រូវបានធ្វើឡើងសម្រាប់សមាជិកប័ណ្ណ ប.ស.ស.។

## ដំណោះស្រាយៈ

- ស្នើសុំរាជរដ្ឋាភិបាល ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងទីប្រឹក្សាជាតិគាំពារសង្គមពិចារណាបង្កើនកញ្ចប់ថវិកាជាតិ (យ៉ាងហោចណាស់ ១.៥% នៃផលិតផលក្នុងស្រុកសរុប) ទៅលើគោលនយោបាយកិច្ចគាំពារសង្គមដើម្បីដាក់បញ្ចូលសមាជិកគ្រួសារនៃកម្មករនិយោជិក និងសមាជិកប័ណ្ណ ប.ស.ស. ទៅក្នុងអត្ថប្រយោជន៍នៃគោលនយោបាយនេះផងដែរ។
- ស្នើសុំពង្រឹងគុណភាព ប្រសិទ្ធភាព និងភាពទុកចិត្តនៃសេវាសុខាភិបាលជូនដល់សមាជិកប័ណ្ណ ប.ស.ស. និងសាធារណៈជនទូទៅ។
- ស្នើសុំពង្រីកវិសាលភាពប័ណ្ណសមាជិក ប.ស.ស. ដោយដាក់បញ្ចូលកម្មវិធីត្រួតពិនិត្យតាមដានសុខភាព (early detection) និងបង្កើតកញ្ចប់ថវិកាព្យាបាលជំងឺទៅក្នុងកម្មវិធីបេឡាជាតិរបបសន្តិសុខសង្គមដើម្បីបង្ការ និងបញ្ចៀសផលជះអាក្រក់ដល់សុខភាព និងចំណាយច្រើនលើការព្យាបាល និងសេវាសុខភាព។
- ស្នើសុំបេឡាជាតិពន្លឿនក្នុងការបញ្ជាក់ និងដាក់បញ្ចូលនូវជំងឺវិជ្ជាជីវៈក្នុងប័ណ្ណសមាជិក ប.ស.ស.។





# តម្រូវការទី១១

## ដាក់បញ្ចូល និងទទួលស្គាល់កសិករខ្នាតតូច នៅជនបទពិសេសកសិករជាស្ត្រីក្នុងគោលនយោបាយកិច្ចគាំពារសង្គម គាំទ្របណ្តុះបណ្តាលជំនាញ និងឧបត្ថម្ភទុនលើកសិករខ្នាតតូច

### បញ្ហាដែលកើតមានឡើង៖

- កសិករខ្នាតតូចនៅជនបទជាពិសេសវិស័យប្រព័ន្ធស្បៀងអាហារកំពុងប្រឈមលើបញ្ហាប៉ះពាល់ដល់សុខភាពនៅពេលដែលពួកគេប្រើប្រាស់ថ្នាំពុល ឬសារធាតុគីមីពុលដើម្បីធ្វើការផលិតស្បៀងអាហារដើម្បីផ្គត់ផ្គង់ដល់មនុស្សទាំងអស់គ្នាដែលបរិភោគចំណីអាហារផលិតដោយកសិករ។
- កសិករខ្នាតតូចជាពិសេសស្ត្រីនៅជនបទប្រឈមមុខលើបញ្ហាថែទាំសុខភាពក្នុងមុខរបររបស់ពួកគេដោយត្រូវចំណាយថវិកាច្រើនសម្រាប់ថែទាំសុខភាព និងបង្កើតមុខរបរ។
- គោលនយោបាយ និងប្រព័ន្ធកិច្ចគាំពារសង្គមរើសអើងដោយបានធ្វើការផាត់ចេញកសិករ និងប្រជាពលរដ្ឋជនបទមិនអាចទទួលបានប្រយោជន៍អំពីកម្មវិធីកិច្ចគាំពារសង្គមដែលជាគោលនយោបាយគាំពារដោយរដ្ឋាភិបាល។
- កសិករខ្នាតតូចនៅជនបទពិសេសស្ត្រីមិនមានជំនាញ និងទុនគ្រប់គ្រាន់សម្រាប់ធ្វើការប្រកបមុខរបរចិញ្ចឹមជីវិតព្រោះរដ្ឋមិនទាន់មានគោលនយោបាយជាក់លាក់ក្នុងការបណ្តុះបណ្តាលជំនាញ និងធ្វើការគាំទ្រទុនដល់កសិករខ្នាតតូចប្រកបមុខរបរ។
- ពេលរដូវប្រមូលផល ត្រូវបានឈ្មួញកំណត់តម្លៃទីផ្សារថោក ធ្វើឱ្យពលរដ្ឋគ្មានជម្រើសដោយសារត្រូវបង់ធនាគារ ឬគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។

## ដំណោះស្រាយ៖

- រាជរដ្ឋាភិបាលធ្វើការត្រួតពិនិត្យឡើងវិញលើគោលនយោបាយក្របខណ្ឌកិច្ចគាំពារសង្គម និងធ្វើការចេញប្រកាសទទួលស្គាល់កសិករខ្នាតតូចជាកម្មករក្រៅប្រព័ន្ធផ្លូវការដើម្បីដាក់បញ្ចូលកសិករទទួលបានកិច្ចគាំពារសង្គមក្នុងការថែទាំសុខភាពដើម្បីកាត់បន្ថយភាពក្រីក្រ។
- ក្រុមប្រឹក្សាជាតិកិច្ចគាំពារសង្គមបង្កើនឱ្យមានតំណាងកសិករសម្រាប់ធ្វើការពិគ្រោះយោបល់ និងដាក់បញ្ចូលកសិករជាផ្លូវការក្នុងគោលនយោបាយគាំពារសង្គម។
- រាជរដ្ឋាភិបាលត្រូវធ្វើការរៀបចំគោលនយោបាយដែលជាក់លាក់ដើម្បីធ្វើការបណ្តុះបណ្តាលជំនាញកសិកម្ម និងត្រូវគាំទ្រឧបត្ថម្ភទុនលើកសិករខ្នាតតូច ជៀសវាងកសិករទៅខ្ចីគ្រឹះស្ថានហិរញ្ញវត្ថុដែលមានអត្រាការប្រាក់ខ្ពស់។
- រាជរដ្ឋាភិបាលត្រូវអន្តរាគមន៍ពេលដែលកសិករប្រមូលផល បញ្ចៀសឈ្មួញឆក់ឱកាសបន្ទាបតម្លៃរបស់កសិករក្នុងស្រុក។
- រាជរដ្ឋាភិបាលត្រូវបង្កើននូវប្រព័ន្ធធារាសាស្ត្រដែលអាចឱ្យប្រជាកសិករក្នុងស្រុកខ្នាតតូចធ្វើស្រែចម្ការក្នុងរដូវប្រាំង ។





# តម្រូវការទី១២

## រដ្ឋាភិបាលត្រូវរៀបចំផ្តល់ទីកន្លែងសម្រាប់អ្នកលក់ដូរតូចតាចតាមចិញ្ចើមផ្លូវ ហើយផ្តល់នូវតម្លៃធូរថ្លៃរួមមាន តាមផ្សារ តាមឆ្នេរ និង តំបន់ទេសចរណ៍

### បញ្ហាដែលកើតមានឡើង៖

- អាជីវករលក់ដូរត្រូវបង់ថ្លៃមុខផ្ទះលក់ដូរមួយហើយនៅត្រូវបង់ភាស៊ីច្រើននាក់ដែលមកយកបន្តបន្ទាប់។
- មានការដេកហូតនូវទំនិញដែលត្រូវប្រកបរបរចិញ្ចឹមដូចជា បន្លែ ផ្លែឈើរបស់ពួកគាត់បន្ថែមពីលើភាស៊ីទៀត។
- សន្តិសុខផ្សារបានរឹបអូសដកហូតបន្លែផ្លែឈើអាជីករទៅទុករយៈពេលយូរបណ្តាលឱ្យទំនិញរលួយ និងខូចខាតថវិកាក្នុងការប្រកបមុខរបរប្រចាំថ្ងៃ។
- សន្តិសុខផ្សារប្រើប្រាស់អំពើហិង្សាដោយការគ្រវែង និងទាត់ទំនិញរបស់គាត់ដែលត្រូវលក់ដូរ ថ្នូរ និងប្រាក់កម្រៃ ធ្វើឱ្យប៉ះពាល់ដល់ជីវភាពរបស់គាត់។
- ការដេញអាជីវករដែលជារបរចិញ្ចឹមជីវិតប្រចាំថ្ងៃដោយមិនមានផែនការក្នុងការផ្តល់ទីតាំងឱ្យគាត់លក់បណ្តោះអាសន្នដែលធ្វើឱ្យប៉ះពាល់ដល់ជីវភាព និងការសិក្សាកូនៗនៅក្នុងបន្ទុក។

### ដំណោះស្រាយ៖

- ពន្លឿនការចុះបញ្ជីអាជីវករខ្នាតតូចក្នុងការទទួលបានការគាំពារសង្គម។
- រៀបចំកន្លែងលក់ដូរសម្រាប់អាជីវករតូចតាច មានតម្លៃសមរម្យដែលអាចឱ្យពួកគាត់ប្រកបរបរចិញ្ចឹមជីវិត និងគាំទ្រដល់សមាជិកគ្រួសារជាពិសេសកូនៗរបស់គាត់។
- ចាត់វិធានការយ៉ាងតឹងរឹងចំពោះសន្តិសុខផ្សារ និងអាជ្ញាធរដែលប្រើប្រាស់អំពើហិង្សាលើអាជីវករលក់ដូរតាមផ្សារ និងតាមផ្លូវ។
- កំណត់ទីតាំងឱ្យអាជីវករដែលលក់ដូរតាមតំបន់ទេសចរណ៍ក្នុងតម្លៃសមរម្យដែលអាចឱ្យគាត់មានចំណូលផ្គត់ផ្គង់គ្រួសារ និងបញ្ជូនកូនៗបានរៀនសូត្រ។
- បញ្ឈប់ការដកហូតបន្លែ ផ្លែឈើ ទុកនៅប៉ុស្តិ៍ ឬទីស្នាក់ការដែលទង្វើនេះបានធ្វើឱ្យអ្នកលក់ដូរតូចតាចបាត់បង់ទុនបន្តិចបន្តួចដើម្បីចិញ្ចឹមជីវិត។

# តម្រូវការទី១៣

## ពង្រឹងគុណភាពនៃការបង្រៀនក្នុងម៉ោងរដ្ឋ បង្កើនចំនួនអាហារូបករណ៍សម្រាប់ជំនាញសិក្សាថ្នាក់ឧត្តមសិក្សា និងកន្លែងស្នាក់នៅឥតគិតថ្លៃ ជាពិសេសក្មេងស្រី



**បញ្ហាដែលកើតមានឡើង៖**

- នៅតាមសាលារដ្ឋគ្រូបង្កើនម៉ោងបង្រៀនគួរដោយមិនផ្តោតលើគុណភាពនៃការអប់រំក្នុងម៉ោងសិក្សា ជាហេតុផលនាំឱ្យការអប់រំមិនមានគុណភាព សិស្សដែលមានជីវភាពក្រីក្រមិនមានលទ្ធភាពបង់ប្រាក់រៀនគួរ ហើយបាត់បង់ឱកាសក្នុងការបន្តការសិក្សា។
- សិស្សនៅតាមបណ្តាខេត្តមួយចំនួនជាពិសេសស្ត្រីសម្រេចចិត្តមិនបន្តការសិក្សាថ្នាក់ឧត្តមសិក្សា ដោយសារតែមិនមានលទ្ធភាពគ្រប់គ្រាន់នៅក្នុងការជួលកន្លែងស្នាក់នៅ។
- ខ្វះមធ្យោបាយធ្វើដំណើរសម្រាប់សិស្សនៅជនបទដាច់ស្រយាលទទួលបានការសិក្សាបន្តធ្វើឱ្យក្មេងស្រីទម្លាក់ចោលការសិក្សាព្រោះកត្តាសុវត្ថិភាព និងជីវភាព។

**ដំណោះស្រាយ៖**

- ក្រសួងអប់រំត្រូវពង្រឹងគុណភាពលើការអប់រំ ហើយចុះត្រួតពិនិត្យជាក់លាក់លើការបង្រៀនរបស់គ្រូ កាត់បន្ថយការបង្រៀនគួរ ហើយងាកមកពង្រឹងគុណភាព ឬបន្ថែមម៉ោងនៃការបង្រៀននៅម៉ោងរដ្ឋ។
- បង្កើនវប្បធម៌អានសៀវភៅដោយមានបណ្ណាល័យនៅគ្រប់សាលាជាពិសេសនៅតាមខេត្ត។
- បង្កើនទីតាំងសិក្សាក្រៅប្រព័ន្ធឱ្យបានកាន់តែទូលំទូលាយ និងនៅជិតកម្មការិនីរោងចក្រ និងសម្របសម្រួលម៉ោងសិក្សាដែលអំណោយផលដល់កម្មការិនីដែលលមានបំណងចង់បន្តការសិក្សាបណ្តើរ ធ្វើការបណ្តើរ។
- ផ្តល់ការគាំពារ និងឧបត្ថម្ភដល់សិស្សក្រីក្រជាសម្ភារៈសិក្សា។
- បង្កើនកន្លែងស្នាក់នៅឥតគិតថ្លៃ និងបង្កើនចំនួនអាហាររូបករណ៍នៅថ្នាក់ឧត្តមសិក្សា ជាពិសេសក្មេងស្រី។
- រាជរដ្ឋាភិបាល និងក្រសួងទទួលបន្ទុកគួរតែបង្កើនកញ្ចប់ថវិកាក្នុងការបន្ថែមនូវចំនួនអាហារូបករណ៍តាមជំនាញដែលមាននៅក្នុងទីផ្សារការងារឱ្យបានច្រើន។
- រាជរដ្ឋាភិបាល និងក្រសួងទទួលបន្ទុកគួរតែផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីឱកាសអាហារូបករណ៍លើមុខជំនាញសិក្សាថ្នាក់ឧត្តមសិក្សា និងឱកាសអាហារូបករណ៍លើការស្នាក់នៅប្រកបដោយតម្លាភាព។



# តម្រូវការទី១៤

## រដ្ឋាភិបាលផ្តល់សេវាជួយដល់ស្ត្រីពិសេសស្ត្រីមានពិការភាពក្នុងការទទួលសេវាគាំពារផ្នែកសុខភាពផ្លូវចិត្ត និងផ្លូវច្បាប់

### បញ្ហាដែលកើតមានឡើង៖

- មានការព្រងើយកន្តើយ និងមិនបានបង្កើតយន្តការក្នុងការគាំទ្រដល់ស្ត្រីជាពិសេសកុមារីដែលជាជនមានពិការភាព ផ្នែកសតិ និងការរីកចម្រើនយឺតលើសតិបញ្ញា។
- ផ្នត់គំនិតសង្គមក្នុងសហគមន៍នៅមានភាពរើសអើងលើជនរងគ្រោះដោយសារតែមិនមានការអប់រំតាមមូលដ្ឋាន ការបន្ទោសលើជនរងគ្រោះនៅពេលមានករណីរំលោភបំពាន។
- អាជ្ញាធរនៅមានឥរិយាបថរើសអើងនៅពេលដែលពួកគាត់ទទួលរងអំពើហិង្សាយេនឌ័រ។
- ការកាត់សេចក្តីចំពោះជនប្រព្រឹត្តមិនត្រូវបានអនុវត្តទៅតាមច្បាប់នៅតែធ្វើការដោះស្រាយក្រៅប្រព័ន្ធតុលាការ។
- អាជ្ញាធរមិនមានធនធានគ្រប់គ្រាន់ក្នុងការដោះស្រាយ និងកំណត់មុខសញ្ញាជនប្រព្រឹត្ត។

### ដំណោះស្រាយ៖

- ក្រុមអាជ្ញាធរត្រូវធានាឱ្យមានការដោះស្រាយនូវបញ្ហាកើតឡើងដោយមានទាំងជំនាញ មិនមានឥរិយាបថរើសអើង មិនមានកាយវិការ និងភាសាបន្ទោសចំពោះជនរងគ្រោះ ដោះស្រាយបញ្ហាដោយសុចរិតភាព។
- មិនធ្វើការពន្យាពេលលើបណ្តឹងរបស់ជនរងគ្រោះ មិនព្យាយាមដោះស្រាយក្រៅប្រព័ន្ធតុលាការនៅពេលមានបណ្តឹងករណីរំលោភផ្លូវភេទ។
- អាជ្ញាធរនៅមូលដ្ឋានត្រូវធ្វើសកម្មភាពផ្តល់វគ្គបណ្តុះបណ្តាលនៅតាមមូលដ្ឋានអំពីបញ្ឈប់វប្បធម៌បន្ទោសជនរងគ្រោះនៅពេលដែលមានករណីរំលោភបំពាន។
- អាជ្ញាធរនៅថ្នាក់មូលដ្ឋានត្រូវមានធនធានមនុស្ស សម្ភារៈ ឧបករណ៍គ្រប់គ្រាន់ដើម្បីធ្វើឱ្យប្រាកដថាពួកគាត់មិនត្រូវបានផាត់ចេញដោយសារពិការភាពរបស់ពួកគាត់។
- ជនមានពិការភាពជាពិសេសស្ត្រីទទួលបានសេវាគាំពារសង្គម ការឆ្លើយតបដោយមិនមានការរើសអើង។

# តម្រូវការទី១៥

ធ្វើវិសោធនកម្មច្បាប់ និងប្រកាសបេឡាជាតិរបបសន្តិសុខសង្គមដោយកែសម្រួលលក្ខខណ្ឌតម្រូវឱ្យនិយោជកនៃសហគ្រាសនោះបានបង់ប្រាក់ភាគទាន៩ខែជាប់លាប់ ទើបកម្មករជាស្ត្រីមានផ្ទៃពោះទទួលបានប្រាក់ឧបត្ថម្ភ៧០ភាគរយនៃប្រាក់ជាប់ភាគទាន



## បញ្ហាដែលកើតមានឡើង៖

- លុះត្រាសាម៉ីខ្លួនដែលជាកម្មករមានការដឹងជាក់ច្បាស់ភ្លាមនៅពេលខ្លួនមិនមានរដូវ ហើយធ្វើតេស្តទឹកនោមភ្លាមឃើញថាមានកូនត្រូវប្រញាប់រត់ទៅប្រាប់រដ្ឋបាលរបស់ក្រុមហ៊ុនក្នុងការចាប់ផ្តើមជូនដំណឹងទៅបេឡាជាតិរបបសន្តិសុខសង្គមក្នុងការបង់ភាគទានបន្ថែមភ្លាមៗ។
- ស្ថានភាពជាក់ស្តែងកម្មករអាចធ្វើការតេស្តទឹកនោមយឺតពេល២ខែ ឬទៅ៣ខែ ក្រោយពេលបាត់រដូវ ដូច្នេះភាពយឺតយ៉ាវមិនបានទទួលបានការគាំពារពីបេឡាជាតិរបបសន្តិសុខសង្គម ព្រោះលុះត្រាបានបង់ភាគទាន០៩ខែជាប់លាប់សិន (យោងលក្ខខណ្ឌរបស់ ប.ស.ស.)។
- ការរើសអើងដោយប្រយោលចំពោះស្ត្រីមានផ្ទៃពោះពីនិយោជកក្នុងអំឡុងពេលអនុវត្តកិច្ចសន្យាការងារបានធ្វើឱ្យនិយោជកគេចវេសការទទួលខុសត្រូវក្នុងការបង់ភាគទាន០៩ខែជាប់លាប់នៃបេឡាជាតិរបបសន្តិសុខសង្គម។

## ដំណោះស្រាយ៖

- លុបចេញនូវលក្ខខណ្ឌដែលតម្រូវឱ្យមានការបង់ភាគទានរហូតដល់ទៅ០៩ខែជាប់លាប់នៃរបបថែទាំសុខភាពសម្រាប់ស្ត្រីមានផ្ទៃពោះ ទើបទទួលបានប្រាក់ឧបត្ថម្ភចំនួន៧០ភាគរយនៃប្រាក់ជាប់ភាគទាន ព្រោះលក្ខខណ្ឌនេះមិនមែនជាលក្ខខណ្ឌការពារកម្មករពិតប្រាកដ ឬអ្នកងាយរងគ្រោះនោះទេ។
- របបថែទាំសុខភាពសម្រាប់ស្ត្រីមានផ្ទៃពោះគួរទទួលបានការគាំពារជាពិសេស ហើយមានប្រសិទ្ធភាពភ្លាមគឺទទួលបាន៧០ភាគរយនៃប្រាក់ជាប់ភាគទាននៅពេលដែលចាប់ផ្តើមចូលបំពេញការងារដោយមិនត្រូវរង់ចាំរហូតដល់បានបង់ភាគទាន០៩ខែជាប់លាប់នោះឡើយ។
- ដាក់ទោសទណ្ឌទាំងពិន័យជាសាច់ប្រាក់ រួមទាំងទោសព្រហ្មទណ្ឌដោយមិនមានការលើកលែងចំពោះការរើសអើងទាំងឡាយណា ដោយប្រយោល ឬផ្ទាល់ពីសំណាក់និយោជកមកលើស្ត្រីមានផ្ទៃពោះ មកចំពោះកម្មករនិយោជិក។



# តម្រូវការទី១៦

## ពង្រីកទីផ្សារការងារក្នុងស្រុកបង្កើនជំនាញថ្មី រួមទាំងពន្លឿនការអនុវត្តគោលនយោបាយផ្តល់ប្រាក់ឧបត្ថម្ភអំឡុងពេលបាត់បង់ប្រាក់ចំណូល ឬ អត់ការងារធ្វើ ជាពិសេសសម្រាប់ស្ត្រី និងយុវជន

### បញ្ហាដែលកើតមានឡើង៖

- វិស័យឯកជនមិនមានទំនួលខុសត្រូវក្នុងវិបត្តិកូវីដ១៩ និយោជកបានយកឱកាសរំសាយ និងបញ្ឈប់ការងាររួមបើទោះសហគ្រាស គ្រឹះស្ថាននោះមិនក្ស័យធននោះទេ មិនតែប៉ុណ្ណោះក្រុមហ៊ុន ខ្វះកម្លាំងកម្មករ ហើយថែមទាំងត្រូវការកម្លាំងកម្មករធ្វើការងារបន្តមកទៀត។
- ស្ថានភាពនេះកម្មករដែលធ្វើការទទួលបានការគាំពារក្នុងប្រព័ន្ធបានធ្លាក់ក្នុងស្ថានភាពក្រៅប្រព័ន្ធដោយធ្វើការមិនទទួលបានចុះបញ្ជីក្នុងបេឡាជាតិ និងការងារមានគ្រោះថ្នាក់ មិនមានប្រាក់ចំណូលទៀងទាត់។
- ប្រជាពលរដ្ឋអត់ការងារធ្វើច្រើនត្រូវបានវិស័យឯកជនឆក់ឱកាស ហើយកម្មករទទួលបានប្រាក់ឈ្នួលទាបដោយសារទីផ្សារការងារចង្អៀត។
- បំណុលរួមទាំងការប្រាក់មានការកើនឡើង។

### ដំណោះស្រាយ៖

- បង្កើនការទាញវិស័យឯកជនឱ្យមានទំនួលខុសត្រូវក្នុងសង្គម រដ្ឋាភិបាលត្រូវពិនិត្យមើលស្ថានភាពរបស់ក្រុមហ៊ុនទាំងនោះមិនអនុញ្ញាតឱ្យក្រុមហ៊ុន ឬវិស័យឯកជនបកស្រាយ ឬឆក់ឱកាសលើស្ថានភាពអ្នករងគ្រោះកំពុងរងគ្រោះខ្លាំងក្នុងស្ថានភាពវិបត្តិការរីករាលដាលនៃមេរោគផ្សេងៗនោះទេ។
- ធានាដល់ការរស់នៅរបស់ពលរដ្ឋប្រកបដោយជីវិតថ្លៃថ្នូរក្នុងនាមជាមនុស្សដោយការគាំទ្រជាសាច់ប្រាក់ក្នុងអំឡុងពេលដែលកម្មករបាត់បង់ការងារជាបណ្តោះអាសន្ន។
- ដើម្បីឆ្លើយតបទីផ្សារការងារថ្មី ផ្តល់ជំនាញបន្ថែមក្នុងអំឡុងពេលទទួលបានកម្មវិធី "ការឧបត្ថម្ភសាច់ប្រាក់អត់ការងារធ្វើ" ទឹកប្រាក់នេះគឺជាទឹកប្រាក់ដែលអាចយកមកចាត់ចែង និងដោះស្រាយជីវភាពប្រចាំថ្ងៃ។
- ដំណោះស្រាយនេះរដ្ឋបានធានាដល់សុខមាលភាពរបស់ប្រជាពលរដ្ឋ។ រាជរដ្ឋាភិបាលមិនអនុញ្ញាតឱ្យវិស័យឯកជន សហគ្រាស គ្រឹះស្ថាន បញ្ឈប់ ឬរំសាយកម្មករដោយឆក់ឱកាសក្នុងស្ថានភាពណាមួយ។ កម្មករនៅរក្សាបានការងារ អត្រាភាពអត់ការងារធ្វើត្រូវបានថយចុះ។ រាជរដ្ឋាភិបាលបង្កើនការទទួលខុសត្រូវចំពោះពលរដ្ឋ។

# ករណីសិក្សាទី១៧

## ពន្លឿនការចុះបញ្ជីពលរដ្ឋដែលធ្វើការក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធតាមរយៈនិរាករណ៍ប្រកាសអន្តរក្រសួង ៤០៤


© ភ្នំពេញ ប៉ុស្ដិ៍

### បញ្ហាដែលកើតមានឡើង៖

- ការកំណត់និយមន័យដែលមាននៅក្នុងប្រកាសដែលចេញដោយអន្តរក្រសួងមិនមានភាពស៊ីសង្វាក់គ្នាជាមួយច្បាប់ស្តីពីបេឡាជាតិរបបសន្តិសុខសង្គមដែលចេញកាលពីឆ្នាំថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩។
- ប្រកាសអន្តរក្រសួង ៤០៤ បានចែងថា៖ «កម្មករសេដ្ឋកិច្ចក្រៅប្រព័ន្ធគឺជាកម្មករដែលធ្វើការតិចជាង៨ម៉ោងក្នុងមួយសប្តាហ៍»។ និយមន័យនេះមិនឆ្លុះបញ្ចាំងពីស្ថានភាពជាក់ស្តែងរបស់ពលរដ្ឋខ្មែរដែលធ្វើការក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ត្បិតពលរដ្ឋខ្មែរភាគច្រើនធ្វើការងារច្រើនជាង៨ម៉ោងក្នុងមួយសប្តាហ៍។ ប្រកាសនេះបានរារាំងឱ្យពលរដ្ឋធ្វើការក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធរាប់ម៉ឺននាក់ (ជាពិសេសស្ត្រីលក់ដូរតាមដងផ្លូវ អ្នករត់កង់បី និងបុគ្គលិកផ្នែកកម្សាន្ត) មិនអាចទទួលបានអត្ថប្រយោជន៍ និងការគាំពារពីគោលនយោបាយកិច្ចគាំពារសង្គមមានដូចជា៖ កម្មវិធីផ្ទេរសាច់ប្រាក់សម្រាប់ម្តាយនិងទារក ប័ណ្ណសមាជិក ប.ស.ស. និងកម្មវិធីសន្តិសុខប្រាក់ចំណូលពេលបាត់បង់ការងារ និងគ្មានការងារធ្វើកំឡុងពេលកូវីដ-១៩ជាដើម។
- កម្មករផ្នែកដឹកជញ្ជូនភ្ញៀវ (PassApp, Grab...) និងដឹកជញ្ជូនអាហារតាមផ្ទះ (Food Panda...) មានការចំណាយទុនច្រើនក្នុងការភ្ជាប់សេវាកម្មនេះ (ទិញទូរស័ព្ទខ្លួនឯង ទិញកង់បីបង់រំលោះ) ធ្វើការច្រើនម៉ោងដើម្បីទទួលបានប្រាក់កម្សុងពីក្រុមហ៊ុន។
- ក្រុមហ៊ុនផ្នែកដឹកជញ្ជូនភ្ញៀវ (PassApp, Grab...) និងដឹកជញ្ជូនអាហារតាមផ្ទះ (Food Panda...) ដែលភ្ជាប់ជាមួយ App មានបុគ្គលិករាប់ពាន់នាក់ទូទាំងប្រទេស ប៉ុន្តែក្រុមហ៊ុនមិនទាន់បានធ្វើការចុះបញ្ជី និងបង់វិភាគទាន ប.ស.ស. ជូនដល់បុគ្គលិកខ្លួនឡើយ។

## ដំណោះស្រាយ៖

- រាជរដ្ឋាភិបាលពិនិត្យនិរករណ៍ប្រកាសអន្តរក្រសួង ៨០៤ ដើម្បីបង្កភាពងាយស្រួលដល់ពលរដ្ឋធ្វើការសេដ្ឋកិច្ចប្រព័ន្ធចុះបញ្ជី និងទទួលបានការការពារ និងអត្ថប្រយោជន៍ពីគោលនយោបាយគាំពារសង្គម ជាពិសេសគឺការទទួលបានប័ណ្ណសមធម៌ (ឬប័ណ្ណក្រីក្រ) និងប័ណ្ណសមាជិក ប.ស.ស.។
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងបេឡាជាតិរបបសន្តិសុខសង្គមត្រូវពិចារណា និងបង្កយន្តការដែលកម្មករក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធអាចបង់វិភាគទាន (ដោយមានវិភាគទានបន្ថែមពីរដ្ឋ) ដើម្បីទទួលអត្ថប្រយោជន៍ និងប័ណ្ណសមាជិក ប.ស.ស.។
- ក្រសួងមហាផ្ទៃ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវធានា និងបង្កភាពងាយស្រួលជូនដល់កម្មករសេដ្ឋកិច្ចក្រៅប្រព័ន្ធដើម្បីទទួលបានឯកសារអត្តសញ្ញាណ (ឧ.ទា លិខិតបញ្ជាក់ទីលំនៅ ឬឯកសារយោងផ្សេងៗ) ដើម្បីផ្តល់ភាពងាយស្រួលដល់ពួកគេស្នើសុំប័ណ្ណសមធម៌ (ឬប័ណ្ណក្រីក្រ) និងប័ណ្ណសមាជិក ប.ស.ស.។
- ក្រសួងពាណិជ្ជកម្ម ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងបេឡាជាតិសន្តិសុខសង្គមត្រូវបង្កើតច្បាប់ដែលតម្រូវឱ្យក្រុមហ៊ុនផ្នែកដឹកជញ្ជូនភ្ញៀវ (PassApp, Grab...) និងដឹកជញ្ជូនអាហារតាមផ្ទះ (Food Panda...) ដែលភ្ជាប់ជាមួយ App ធ្វើការចុះបញ្ជី និងបង់វិភាគទាន ប.ស.ស. សម្រាប់បុគ្គលិករបស់ខ្លួន។



© ភ្នំពេញ ប៉ុស្តិ៍

## ចូលរួមគាំទ្រដោយៈ

១. សហពន្ធ័សហជីពកម្មករចំណីអាហារ និងសេវាកម្មកម្ពុជា (CFSWF)
២. គណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជាដើម្បីអនុសញ្ញាលុបបំបាត់រាល់ទំរង់នៃការរើសអើងលើស្ត្រីភេទ (CEDAW)
៣. សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA)
៤. សមាគមខ្មែរកម្ពុជាក្រោម ដើម្បីសិទ្ធិមនុស្ស និងអភិវឌ្ឍន៍ (KKKHRDA)
៥. អង្គការមជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ (CLEC)
៦. សមាគមមន្ត្រីរាជការឯករាជ្យកម្ពុជា (CICA)
៧. អង្គការកម្មវិធីអភិវឌ្ឍន៍ធនធានយុវជន (YRPD)
៨. អង្គការសម្ព័ន្ធភាពការពារសិទ្ធិមនុស្សកម្ពុជា (CHRAC)
៩. សមាគមសម្ព័ន្ធនិស្សិតបញ្ញវន្តខ្មែរ (KSILA)
១០. អង្គការ តម្លាភាព កម្ពុជា (Transparency International Cambodia)
១១. សហព័ន្ធសហជីពឯករាជ្យ (INTUFE)
១២. អង្គការនារីដើម្បីសន្តិភាព (WPM)
១៣. បណ្តាញយុវជនកម្ពុជា(CYN)
១៤. សមាគមសម្ព័ន្ធសហគមកសិករ កម្ពុជា (CCFC)
១៥. សមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យ (CITA)
១៦. មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស សង់ត្រាល់ (CENTRAL)
១៧. សមាគមធាងត្នោត (STT)
១៨. អង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ (LICADHO)
១៩. ក្លាហាន (Klahaan)
២០. សហព័ន្ធសហជីពកម្មករសំណង់ និងព្រៃឈើកម្ពុជា (BWTUC)
២១. មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR)
២២. សហភាពផ្ទះសាមគ្គី (SHC)
២៣. សហព័ន្ធសហជីពកម្ពុជា (CATU)
២៤. សហព័ន្ធសហជីពកម្មករនិយោជិតវិស័យទេសចរណ៍កម្ពុជា (CTWUF)
២៥. សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា (CCAWDU)
២៦. សហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរនៃក្រុមហ៊ុនណាហ្គាវើល (LRSU)
២៧. សមាគមការពារសិទ្ធិមនុស្ស និង អភិវឌ្ឍន៍នៅកម្ពុជា (ADHOC)
២៨. អង្គការសមធម៌កម្ពុជា (EC)
២៩. គណៈកម្មាធិការដើម្បីបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (COMFREL)
៣០. អនាគតយុវជនកម្ពុជាអាស៊ាន (CamASEAN Youth Future)
៣១. វិទ្យាស្ថានប្រជាធិបតេយ្យ កម្ពុជា (CID)

ចូលរួមគាំទ្រ និងផលិតដោយ